**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៧៦ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី

## បទប្បញ្ញត្តិដែលត្រូវអនុវត្តចំពោះ ភ្នាក់ងារធានារ៉ាប់រង និង ជើងសាធានារ៉ាប់រង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៩៦ ចុះ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនឹងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញការចាំបាច់នៃការងារគ្រប់គ្រង ។

## សំរេច

**ប្រការ ១.-**

ភ្នាក់ងារធានារ៉ាប់រង មិនអាចរៀបចំ ឬកាន់កាប់ដោយប្រើសិទ្ធិរៀបចំកិច្ចសន្យាធានារ៉ាប់រង ក្នុងនាមជាភ្នាក់ងាររបស់ក្រុមហ៊ុនធានារ៉ាប់រងណាមួយទេ ប្រសិនបើភ្នាក់ងារធានារ៉ាប់រងមិនបានធ្វើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយក្រុមហ៊ុនធានារ៉ាប់រងនោះ និងសាមីក្រុមហ៊ុនធានារ៉ាប់រងមិនបានអនុញ្ញាត ឱ្យភ្នាក់ងារធានារ៉ាប់រង រៀបចំ ÷

ក- កិច្ចសន្យាធានារ៉ាប់រងនោះ ,

ខ- កិច្ចសន្យាធានារ៉ាប់រងណាមួយ ,ឬ

គ- ក្រុមនៃកិច្ចសន្យាធានារ៉ាប់រង ដែលក្នុងនោះរួមមានកិច្ចសន្យាធានារ៉ាប់រងនោះ , ក្នុងនាមជាភ្នាក់ងារធានារ៉ាប់រងរបស់ក្រុមហ៊ុនខ្លួនទេ ។

**ប្រការ ២.-**

ក្រុមហ៊ុនធានារ៉ាប់រង ដែលមានអាជ្ញាប័ណ្ណ ឱ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា មិនអាចបង្ក ឬ អនុញ្ញាតឱ្យភ្នាក់ងារធានារ៉ាប់រងណាមួយរៀបចំឬកាន់កាប់ដោយប្រើសិទ្ធិរៀបចំកិច្ចសន្យាធានារ៉ាប់រង ក្នុងនាមជាភ្នាក់ងាររបស់ក្រុមហ៊ុនខ្លួនដោយមិនមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងសាមីក្រុមហ៊ុនជាមួយនឹងភ្នាក់ងារនោះ និងសាមីភ្នាក់ងារធានារ៉ាប់រង មិនបានទទួលការអនុញ្ញាត ឱ្យរៀបចំ ÷

ក- កិច្ចសន្យាធានារ៉ាប់រងនោះ ,

ខ- កិច្ចសន្យាធានារ៉ាប់រងណាមួយ ឬ

គ- ក្រុមនៃកិច្ចសន្យាធានារ៉ាប់រង ដែលក្នុងនោះ រួមមានកិច្ចសន្យាធានារ៉ាប់រង នោះ , ក្នុងនាមជាភ្នាក់ងាររបស់ ក្រុមហ៊ុនខ្លួនទេ ។

**ប្រការ ៣.-**

ខ្លឹមសារនៃប្រការ ( ១ ) និងប្រការ ( ២ ) ខាងលើមិនអនុវត្តចំពោះនិយោជិតរបស់ក្រុមហ៊ុនធានារ៉ាប់រងក្នុងការបំរើសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន និង ដែលសាមីក្រុមហ៊ុនបានប្រគល់សិទ្ធិ ឱ្យនោះរួច ។

**ប្រការ ៤.-** ភ្នាក់ងារធានារ៉ាប់រងទាំងអស់ ពេលបានទទួលការយល់ព្រមឱ្យធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ ហើយដែលបានធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនធានារ៉ាប់រង ដទៃទៀតនោះ ត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីការអនុវត្តនីរបស់ខ្លួន ។ ទន្ទឹម នឹងនោះត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ នូវច្បាប់ថតចម្លងកិច្ចព្រមព្រៀងរវាង សាមីភ្នាក់ងារជាមួយក្រុមហ៊ុនធានារ៉ាប់រង ។

ប្រការ ៥.-

ភ្នាក់ងារធានារ៉ាប់រងទាំងអស់ដែលបានទទួលអាជ្ញាប័ណ្ណឱ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា មិនអាចធ្វើជាភ្នាក់ងារ ឱ្យក្រុមហ៊ុនធានារ៉ាប់រង ដែលចុះបញ្ជីនៅក្រៅព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

ប្រការ ៦.-

ជើងសាធានារ៉ាប់រង ដែលមានអាជ្ញាប័ណ្ណ ឱ្យ ធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកមួយ ឬច្រើនដើម្បីធ្វើជាក្រុមហ៊ុនមេសំរាប់ចេញវិញ្ញាបនប័ត្រធានារ៉ាប់រងចំពោះអតិថិជនរបស់ខ្លួន ។

ទន្ទឹមនឹងនោះជើងសាធានារ៉ាប់រងទាំងអស់ត្រូវ អនុវត្តកាតព្វកិច្ចផ្ទេរសំពៀតប័ណ្ណសន្យារ៉ាប់រងដែលសាមីជើងសាធានារ៉ាប់រង បានទទួលធ្វើជាអន្តរការីនោះ ចំនួន ២០% ជូនរដ្ឋ ។

ជើងសាធានារ៉ាប់រងទាំងអស់ត្រូវធ្វើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវច្បាប់ថតចម្លងកិច្ចព្រមព្រៀងរវាងសាមីជើងសាធានារ៉ាប់រង ជាមួយក្រុមហ៊ុនធានារ៉ាប់រងមេ និង ច្បាប់ថតចម្លងកិច្ចព្រមព្រៀង រវាងសាមីជើងសាធានារ៉ាប់រងជាមួយទីផ្សារក្រៅប្រទេសកម្ពុជា ។

ប្រការ ៧.-

ការបង់នូវចំនួនទឹកប្រាក់ណាមួយទៅឱ្យភ្នាក់ងារធានារ៉ាប់រង / ជើងសាធានារ៉ាប់រងដោយអ្នកត្រូវបានធានារ៉ាប់រង ឬ តំណាងរបស់អ្នកត្រូវបានធានារ៉ាប់រង អនុលោមតាមកិច្ចសន្យាធានារ៉ាប់រងដែលបានរៀបចំ ឬ ធ្វើឡើងដោយភ្នាក់ងារធានារ៉ាប់រង / ជើងសាធានារ៉ាប់រងទោះជាការបង់បុព្វលាភរ៉ាប់រង ឬ ជាការបង់ប្រាក់អ្វីផ្សេងក៏ដោយ គឺត្រូវរួចផុតពីការទទួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រងចំពោះទឹកប្រាក់នៃការបង់នោះ ។ ការបង់ប្រាក់នោះចាត់ទុកជាការបង់ប្រាក់ជូនក្រុមហ៊ុនធានារ៉ាប់រង ដោយអ្នកត្រូវបានធានារ៉ាប់រង ដែរ ។

ប្រការ ៨.-

ការបង់ប្រាក់ដោយក្រុមហ៊ុនធានារ៉ាប់រង ទៅឱ្យភ្នាក់ងារ / ជើងសាធានារ៉ាប់រង នូវចំនួនទឹកប្រាក់ត្រូវបង់ជូនអ្នកត្រូវបានធានារ៉ាប់រង ទោះជាក្រោមរូបភាពជាទឹកប្រាក់ធ្វើសំណង ជាបុព្វលាភរ៉ាប់រងបង្វិលជូនវិញ ឬជាទឹកប្រាក់អ្វីផ្សេងក៏ដោយ ដែលទាក់ទងនឹងកិច្ចសន្យាធានារ៉ាប់រង មិនត្រូវរួចផុតពីការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រង ចំពោះអ្នកត្រូវបានធានារ៉ាប់រង នូវទឹកប្រាក់ដែលត្រូវបង់នោះឡើយ ។

**ប្រការ ៩.-**

កិច្ចព្រមព្រៀងទាំងឡាយណាដែលអះអាងផ្ទុយពីប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១០.-**

ប្រការ ៩ នៃប្រកាសនេះមិនអាចទុកជានិរាករណ៍នូវកិច្ចព្រមព្រៀងរវាងភ្នាក់ងារធានារ៉ាប់រង / ជើងសាធានារ៉ាប់រង និង អ្នកត្រូវបានធានារ៉ាប់រងដែលអនុញ្ញាតឱ្យភ្នាក់ងារ / ជើងសាជួយសំរួលទូទាត់នូវបុព្វលាភរ៉ាប់រងជូនក្រុមហ៊ុនធានារ៉ាប់រង ជំនួសខ្លួននោះឡើយ ។

**ប្រការ ១១.-**

ភ្នាក់ងារធានារ៉ាប់រង / ជើងសាធានារ៉ាប់រងទាំងឡាយមិនអាចផ្តល់ជូននូវកិច្ចសន្យាធានារ៉ាប់រង ឬសំណើ ឱ្យចុះកិច្ចសន្យាធានារ៉ាប់រងដល់ជនណាម្នាក់ដោយមិនបានប្រាប់ឱ្យគេដឹងអំពី÷

ក- ឈ្មោះរបស់ក្រុមហ៊ុនធានារ៉ាប់រង .

ខ- ទំនាក់ទំនងរបស់ខ្លួនជាមួយក្រុមហ៊ុនធានារ៉ាប់រង ,និង

គ- បុព្វលាភរ៉ាប់រងកំណត់ដោយក្រុមហ៊ុនធានារ៉ាប់រងនោះឡើយ ។

**ប្រការ ១២.-**

ភ្នាក់ងារធានារ៉ាប់រង / ជើងសាធានារ៉ាប់រងទាំងឡាយមិនអាចរៀបចំប័ណ្ណសន្យារ៉ាប់រងជាក្រុមសំរាប់មនុស្សពីរនាក់ ឬច្រើននាក់បានទេ កាលបើជនដែលត្រូវបានធានារ៉ាប់រងដោយប័ណ្ណសន្យារ៉ាប់រងជាក្រុមណាម្នាក់ដែលទទួលខុសត្រូវបង់បុព្វលាភរ៉ាប់រង មិនបានបញ្ចេញ ឱ្យមនុស្សក្នុងក្រុមដែលត្រូវបានធានារ៉ាប់រងដោយប័ណ្ណសន្យារ៉ាប់រងជាក្រុមនោះដឹង នូវ ÷

ក- ឈ្មោះរបស់ក្រុមហ៊ុនធានារ៉ាប់រង .

ខ- ទំនាក់ទំនងរបស់ភ្នាក់ងារ / ជើងសានោះជាមួយក្រុមហ៊ុនធានារ៉ាប់រង .

គ- ល័ក្ខខ័ណ្ឌធានា នៃ ប័ណ្ណសន្យារ៉ាប់រងជាក្រុម . និង

ឃ- បុព្វលាភរ៉ាប់រង កំណត់ដោយក្រុមហ៊ុនធានារ៉ាប់រង ទេ ។

**ប្រការ ១៣.-**

ក្រុមហ៊ុនធានារ៉ាប់រងត្រូវទទួលសង ចំពោះជនដែលត្រូវបានធានារ៉ាប់រងដោយប័ណ្ណសន្យារ៉ាប់រងជាក្រុម ប្រសិនបើជនដែលត្រូវបានធានារ៉ាប់រងបានបង់បុព្វលាភរ៉ាប់រងទៅ ឱ្យម្ចាស់ប័ណ្ណសន្យារ៉ាប់រងជាក្រុមរួចហើយ ដោយឥតគិតអំពី ករណីដែលក្រុមហ៊ុនធានារ៉ាប់រង មិនបានទទួលបុព្វលាភរ៉ាប់រងពីម្ចាស់ប័ណ្ណសន្យារ៉ាប់រងជាក្រុម នោះឡើយ ។

**ប្រការ ១៤.-**

ក្រុមហ៊ុនធានារ៉ាប់រង ដែលចេញប័ណ្ណសន្យារ៉ាប់រងជាក្រុមត្រូវបង់នូវទឹកប្រាក់ដែលត្រូវបង់ក្រោមប័ណ្ណសន្យារ៉ាប់រងនេះ ទៅឱ្យជនដែលត្រូវបានធានារ៉ាប់រង ឬ ជនណាម្នាក់មានសិទ្ធិទទួលដោយផ្ទាល់ ។

**ប្រការ ១៥.-**

បទប្បញ្ញត្តិ ទាំងឡាយដែលផ្ទុយ នឹង ខ្លឹមសារនៃប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១៦.-**

ប្រកាសនេះមានវានុភាព គតិយុត្តិ ចាប់ពីថ្ងៃចុះ ហត្ថលេខា ត ទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមទេសរដ្ឋមន្ត្រី
  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ឯកសារ - កាលប្បវត្តិ